ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
No. ២៧០ MoC / M 2002

រាជធានីភ្នំពេញ, ថ្ងៃទី ០៥ ខែ កញ្ញា ឆ្នាំ២០០២

# ប្រកាស

## ស្តីពីការដាក់ឱ្យដេញថ្លៃលើកូតា សំលៀកបំពាក់ ដែលត្រូវនាំចេញទៅសហរដ្ឋអាមេរិក សំរាប់ប្រើប្រាស់ក្នុងឆ្នាំ២០០២

## រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ៥៤/អនក្រ បក ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងប្រព្រឹត្តិទៅនៃក្រសួងពាណិជ្ជកម្ម
- យោងតាមសុពលភាពនៃការបន្ត កិច្ចព្រមព្រៀងពាណិជ្ជកម្មវាយនភ័ណ្ឌ និងផលិតផលវាយនភ័ណ្ឌធ្វើពីកប្បាស ខ្សែន សរសៃសិប្បនិម្មិតធ្វើដោយដៃមនុស្ស សរសៃរុក្ខជាតិគ្មានជាតិកប្បាស និងសរសៃល្បាយសូត្ររវាងរាជរដ្ឋាភិបាលកម្ពុជា និង រដ្ឋាភិបាលសហរដ្ឋអាមេរិក ដែលបានចុះហត្ថលេខា កាលពី ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០០១
- បានឃើញការចាំបាច់របស់ក្រសួង

## សំរេច

**ប្រការ១-** គ្រប់រោងចក្រកាត់ដេរទាំងអស់ដែលកំពុងដំណើរការ និងដែលបានចុះបញ្ជី នៅនាយកដ្ឋានប្រពន្ធអនុគ្រោះពាណិជ្ជកម្ម (នាយកដ្ឋាន **GSP** ) នៃក្រសួងពាណិជ្ជកម្ម មុនថ្ងៃទី

១៧ ខែកញ្ញា ឆ្នាំ២០០២ ត្រូវបានអញ្ជើញឱ្យមកដេញថ្លៃ តាមប្រភេទផ្សេងៗ នៃ **Quota** ទៅតាមលទ្ធភាពផលិតកម្មរបស់ខ្លួន ។

**ប្រការ២-** រោងចក្រនីមួយៗត្រូវបានអនុញ្ញាតឱ្យដេញថ្លៃ យកបរិមាណតិច ឬស្មើនឹងបរិមាណនៃកូតា ដែលដាក់ ឱ្យដេញថ្លៃ តាមប្រភេទនីមួយៗនៃ Quota ដូចខាងក្រោម :

| ប្រភេទ | បរិមាណដេញថ្លៃ (DZ) | ប្រភេទ | បរិមាណដេញថ្លៃ (DZ) |
|---|---|---|---|
| ៣៣១/៦៣១ | ២៥.០០០ | ៣៤៧/៣៤៨/៦៤៧/៦៤៨ | |
| ៣៣៤/៦៣៤ | ៥.០៥៣ | ៣៥២/៦៥២ | |
| ៣៣៥/៦៣៥ | ៣.៧០០ | ៤៣៥ | ១០.៨៣៧" |
| ៣៣៨/៣៣៩ | ៧៥៤ | ៤៣៨ | ១៨.៥៧៦ |
| ៣៤០/៦៤០ | ១៥៦.១៧២ | ៤៤៥/៤៤៦ | ២៥.៨៧៨ |
| ៣៤៥ | ៣៨.២៨៩ | ៦៣៨/៦៣៩ | ២៦៦.១១៥ |
| | | ៦៤៥/៦៤៦ | ១០៤.៦៨០ |

**ប្រការ៣-** ពាក្យសុំដេញថ្លៃនីមួយៗ ត្រូវភ្ជាប់មកជាមួយនូវមូលប្បទានប័ត្រដែលមានការបញ្ជាក់ពីធនាគារ **Certified Check** ដែលមានតំលៃស្មើនឹង ១០% នៃតំលៃដេញថ្លៃសរុប ។ មូលប្បទានប័ត្រនេះ ត្រូវទូទាត់ប្រាក់ជូន គណៈកម្មាធិការគ្រប់គ្រងកូតាសំរាប់នាំចេញ ( Export Quotas Management Committee " EQMC " ) ។ ការបង់ប្រាក់កក់អប្បបរមាមិនគ្រប់ចំនួន ១០% នៃតម្លៃដេញថ្លៃសរុបនឹងចាត់ទុកថា ពាក្យសុំដេញថ្លៃគ្មានប្រសិទ្ធភាព ។ ឧទាហរណ៍ រោងចក្រ A

ដេញថ្លៃ ចំនួន ២០ ០០០ ឡូ តំលៃ ៨ ដុល្លា/ឡូ = ១៦០.០០០ ដុល្លា

ទឹកប្រាក់កក់ ១០ % = ១៦.០០០ ដុល្លា

**ប្រការ៤-** ការដេញថ្លៃក្នុងតំលៃខ្ពស់បំផុតតាម Category នឹងបានទទួលជ័យជំនះ ។ Quota នឹងត្រូវបានបែងចែកដល់អ្នកដេញថ្លៃ ដែលបានទទួលជោគជ័យរហូតដល់បរិមាណ Quota សរុប ត្រូវបានបែងចែកអស់ ។

**ប្រការ៥-** **Quota** ដែលមិនទាន់បែងចែកនឹងបន្តទុកឱ្យអ្នកដេញថ្លៃក្រោយទៀត ។

**ប្រការ៦**- តំលៃនៃការចូលរួមដេញថ្លៃ នឹងត្រូវទទួលបេក ចំពោះរាល់ការបន្ថែមចំនួនទសភាគ ២០ សេន ( រៀល ) នៃប្រាក់ដុល្លាសហរដ្ឋអាមេរិកលើ ថ្លៃឯកត្តាតាមប្រភេទ នីមួយៗ :

| | | | |
|---|---|---|---|
| **Cat ៣៣១/៦៣១** | **0.20$/dpr** | **Cat ៤៣៥** | **1.00$/doz** |
| **Cat ៣៣៤/៦៣៤** | **3.00$/doz** | **Cat ៤៣៨** | **1.00$/doz** |
| **Cat ៣៣៥/៦៣៥** | **3.00$/doz** | **Cat ៤៤៥/៤៤៦** | **0.50$/doz** |
| **Cat ៣៣៨/៣៣៩** | **3.00$/doz** | **Cat ៦៣៨/៦៣៩** | **0.80$/doz** |
| **Cat ៣៤០/៦៤០** | **0.80$/doz** | **Cat ៦៤៥/៦៤៦** | **0.50$/doz** |
| **Cat ៣៤៥** | **1.00$/doz** | | |

**ប្រការ៧**- ពាក្យដេញថ្លៃត្រូវដាក់ជូន ឯកឧត្តមប្រធានគណៈកម្មាធិការគ្រប់គ្រងកូតាសំរាប់នាំចេញ " EQMC " នៃក្រសួងពាណិជ្ជកម្ម ដែលមានទីតាំង នៅអគារជាន់ទី២ លេខ ២០ **B** មហាវិថីព្រះនរោត្តម ។ ពាក្យសុំដេញថ្លៃត្រូវដាក់ក្នុងស្រោមសំបុត្របិទជិត ភ្ជាប់ជាមួយនូវមូលប្បទានប័ត្រ ដែលមានទឹកប្រាក់ចំនួន ១០ % នៃតំលៃដេញថ្លៃសរុបដាក់ក្នុងស្រោមសំបុត្រនោះ ។

**ប្រការ ៨**- កាលបរិច្ឆេទនៃការបើកស្រោមសំបុត្រដេញថ្លៃ គឺនៅថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ២០០២ ចាប់ពីម៉ោង ៨:០០ ព្រឹក នៅទីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម អគារលេខ ២០ អា ជាន់ទី២ មហាវិថីព្រះនរោត្តម ។

**ប្រការ ៩**- កាលបរិច្ឆេទឈប់ទទួលពាក្យដេញថ្លៃគឺនៅថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០០២ វេលាម៉ោង ៥:០០ ល្ងាច ។

**ប្រការ ១០**- លទ្ធផលនៃការដេញថ្លៃ នឹងត្រូវប្រកាសជាសាធារណៈ នៅថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ២០០២ តាមប្រកាសរបស់ក្រសួងពាណិជ្ជកម្ម ។

**ប្រការ ១១**- អ្នកចូលរួមដេញថ្លៃ ដែលបានទទួលជោគជ័យ នឹងអាចប្រើប្រាស់កូតាបាន បន្ទាប់ពីបានទូទាត់តំលៃដេញថ្លៃ ដែលនៅសេសសល់ ៩០ % រួចហើយ ។ កាលបរិច្ឆេទទូទាត់ចុងក្រោយ ត្រូវបានកំណត់ នៅថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ ២០០២ ។

**ប្រការ ១២**- អ្នកដេញថ្លៃដែលបានទទួលជោគជ័យ ប៉ុន្តែខកខានមិនបានទទួលយកកូតារបស់ខ្លួនទៅប្រើប្រាស់ នឹងត្រូវរឹបអូសយកប្រាក់កក់ ១០% ហើយបរិមាណកូតានោះ នឹងបន្តទុក

សំរាប់ដេញថ្លៃលើកក្រោយទៀត ។ ក្រសួងពាណិជ្ជកម្មរក្សាសិទ្ធិក្នុងការ មិនអនុញ្ញាតឱ្យក្រុមហ៊ុននោះ ចូលរួមដេញថ្លៃកូតា លើកក្រោយៗទៀតឡើយ ។

**ប្រការ ១៣-** អ្នកចូលរួមដេញថ្លៃ ដែលមិនបានទទួលជោគជ័យ នឹងត្រូវបានផ្តល់ជូនវិញនូវប្រាក់កក់ ១០% របស់ខ្លួន ចាប់ពីថ្ងៃបន្ទាប់ពីថ្ងៃដេញថ្លៃតទៅ ។

**ប្រការ ១៤-** Quota ដែលបានទទួល តាមរយៈការដេញថ្លៃនេះ ប្រើប្រាស់បានសំរាប់ឆ្នាំសារពើពន្ធ ២០០២ តែប៉ុណ្ណោះ ។

**ប្រការ ១៥-** ការសំរេចចិត្តរបស់ EQMC នៅក្នុងការអនុវត្តការដេញថ្លៃ ជាការសំរេចចុងក្រោយ ។

**ប្រការ ១៦-** នាយកខុទ្ទកាល័យ អគ្គនាយកបច្ចេកទេស ប្រធាននាយកដ្ឋានកាំកុងត្រូល ប្រធាននាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម ប្រធាននាយកដ្ឋានរដ្ឋបាល រាល់ផលិតករសំលៀកបំពាក់ និង សមាជិកគណកម្មាធិការគ្រប់គ្រងកូតាសំរាប់នាំចេញ ត្រូវទទួលអនុវត្តនូវប្រការនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ចម ប្រសិទ្ធ**

ចំលងជូនៈ

- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី និងជាសហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- ក្រសួងសង្គមកិច្ចការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

  " ដើម្បីជ្រាបជាពត៌មាន "
- ទូរទស្សន៍ជាតិ វិទ្យុជាតិ និងសារពត៌មានជាតិ
- រាជកិច្ច ✓
- ឯកសារ កាលប្បវត្តិ



Ministry of Commerce # 20 A & B Preah Norodom Boulevard, Phnom Penh 12205 ( Kingdom of Cambodia )
Minister' s Mobile Phone (855-12) 821888 Facsimile: (855-23) 213288
Staff's Mobile Phones. (855-12) 818883 / 881223 Facsimile: (855-23) 426396